ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារលេខ៖ D229/1/2

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ១៧)

ចំពោះមុខ: ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Steven J. BWANA
ចៅក្រម ន័យ ថុល
ចៅក្រម Chang-Ho CHUNG
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 03 / 2015
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

---

សាធារណៈ (សំណៅកោសលុប)

សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើរបស់គាត់ស្នើសុំសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញលើការដាក់បញ្ចូលចម្លើយសាក្សីនៃសំណុំរឿង០០៤នៅក្នុងសំណុំរឿង០០២/០២

សហព្រះរាជអាជ្ញា:
ជា លាង
Nicholas KOUMJIAN

សហមេធាវីការពារក្តី [redacted]
សូ មូស្សេនី
Suzana TOMANOVIĆ

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

01070201

សំ សុគង់	Christine MARTINEAU
	Barnabe NEKUI
ស៊ិន សុវ៉ន	Martine JACQUIN
	Emmanuel JACOMY
ទី ស្រីនណា	Lyma NGUYEN
វ៉ែន ពៅ	Beini YE

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ ក.ស.ច.ស លើសំណើសុំជាបន្ទាន់របស់គាត់ ស្នើសុំសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីនៃសំណុំរឿង០០៤ នៅក្នុងសំណុំរឿង០០២/០២" ដាក់នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ ("ម្ចាស់បណ្តឹងឧទ្ធរណ៍" និង "បណ្តឹងឧទ្ធរណ៍"[1]។

I. **ប្រវត្តិនីតិវិធី**

1. នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ជាសាធារណនៅក្នុងសំណុំរឿង០០២/១៩-០៩-២០០៧-អវតក ("សំណុំរឿង០០២") នូវ "ការដាក់បង្ហាញចម្លើយសាក្សីរបស់សហព្រះរាជអាជ្ញាអន្តរជាតិពីសំណុំរឿង០០៤" ដែលនៅក្នុងនោះគាត់ថ្លែងថា បានទទួលការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឲ្យដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ២៧ ដែលប្រមូលបាននៅក្នុងសំណុំរឿង០០៤ ("ចម្លើយសាក្សីចំនួន២៧") ដែលទាក់ទិននឹងវគ្គដំបូងនៃសវនាការក្នុងសំណុំរឿង០០២/០២ ជូនអង្គជំនុំជម្រះសាលាដំបូង មេធាវីការពារក្តី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ("ការដាក់បង្ហាញ")[2]។

2. នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ ម្ចាស់បណ្តឹងឧទ្ធរណ៍បានស្នើសហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្តល់នូវការអនុញ្ញាតចូលពិនិត្យមើលឯកសារចំនួនប្រាំ ដែលមានយោងនៅក្នុងការដាក់បង្ហាញ ដែលមានសំណើចំនួនបី ស្នើដោយសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីដាក់បង្ហាញនៅក្នុងសំណុំរឿង០០២ នូវចម្លើយសាក្សីដែលធ្វើនៅក្នុងសំណុំរឿង០០៤ និងសេចក្តីសម្រេចចំនួនពីររបស់សហចៅក្រមអន្តរជាតិទាក់ទិននឹងសំណើទាំងនេះ ដោយបញ្ជាក់ថាឯកសារទាំងនេះជាការចាំបាច់

---

[1] ឯកសារ D229/1/1។

[2] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសជ ការដាក់បង្ហាញកំណត់ហេតុនៃសំណុំរឿង ០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ E319 កថាខណ្ឌ ២។

សម្រាប់គាត់ក្នុងការវាយតម្លៃទៅលើអសមភាពជាក់ស្តែង នៃការប្រព្រឹត្តរវាងអ្នកមិនមែនជាភាគី នៃសំណុំរឿង០០៤ (សំណើសុំឯកសារចំនួនប្រាំ")[3]។

3. នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើសុំឯកសារចំនួនប្រាំ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពន្យល់ថា សេចក្តីសម្រេចរបស់គាត់ក្នុងការអនុញ្ញាតឱ្យបង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន២៧ គឺផ្អែកលើកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការដាក់បង្ហាញដល់ជនសង្ស័យក្នុងសំណុំរឿង០០២ នូវភស្តុតាងដោះបន្ទុក ព្រមទាំងឯកសារផ្សេងៗទៀត ដែលអាចជួយក្នុងការរៀបចំការពារក្តីរបស់ពួកគេ ដែលគាត់បានធ្វើឱ្យមានតុល្យភាព ទៅនឹងតម្រូវការរក្សាភាពសម្ងាត់នៃការស៊ើបអង្កេតក្នុងសំណុំរឿង០០៤[4]។ ចំពោះចំណុចនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្លែងថា គាត់មិនបានពិចារណាទៅលើ "ដំណើរវិវត្តនានានៅក្នុងការស៊ើបអង្កេតសំណុំរឿង០០៤ ដែលបានកាត់បន្ថយសេចក្តីព្រួយបារម្ភមួយចំនួនអំពីភាពសម្ងាត់ ទាក់ទងនឹងសម្ភារៈដែលបានស្នើ" ក្នុងចំណោមរបស់ដទៃទៀត[5]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្លែងថា ឯកសារចំនួនប្រាំដែលបានស្នើសុំដោយម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានចាត់ថ្នាក់ជាឯកសារសម្ងាត់ ឬសម្ងាត់បំផុត ហើយផ្ទុកនូវឯកសារយោងជាច្រើនទៅនឹងសាក្សីនានាក្នុងសំណុំរឿង០០៤ និងភស្តុតាងផងដែរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ដោយហេតុថា ម្ចាស់បណ្តឹងប្រសិនបើចុងក្រោយត្រូវបានចោទប្រកាន់ នឹងមានសិទ្ធិពិនិត្យមើលសេចក្តីសម្រេចណាមួយចេញដោយសហចៅក្រមស៊ើបអង្កេត និងស្វែងរកដំណោះស្រាយសមស្រប ប្រសិនបើគាត់គិតថាសិទ្ធិរបស់គាត់ត្រូវបានរំលោភនោះ សហចៅក្រមស៊ើបអង្កេតមិនយល់ឃើញថា ការដាក់បង្ហាញឯកសារចំនួនប្រាំថាជាការចាំបាច់ នៅក្នុងដំណាក់កាលនេះដើម្បីការពារសិទ្ធិរបស់ម្ចាស់បណ្តឹងឡើយ[6]។

---

[3] សំណើបន្ទាន់របស់ [redacted] សុំឯកសារចំនួនប្រាំដែលយោងនៅក្នុង "ការដាក់បង្ហាញកំណត់ហេតុនៃសំណុំរឿង ០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិ" ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D226។

[4] ដីកាសម្រេចលើសំណើរបស់ជនសង្ស័យសុំឯកសារចំនួនប្រាំ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D226/1 កថាខណ្ឌ ៨-៩។

[5] ដូចខាងលើ កថាខណ្ឌ ១០។

[6] ដូចខាងលើ កថាខណ្ឌ ១២។

អង្គជំនុំជម្រះសាលាដំបូង PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

4. នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ ម្ចាស់បណ្តឹងបានស្នើសហចៅក្រមស៊ើបអង្កេតថា ក) ឬមួយ ពិចារណាឡើងវិញ តាមរយៈការលុបចោល ទៅលើការដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយ សាក្សីចំនួន២៧ ឬមួយ ខ)ពិចារណាឡើងវិញនូវសេចក្តីសម្រេចរបស់គាត់ ដោយលុបចោលការ អនុញ្ញាតឱ្យមេធាវីការពារក្តីចូលពិនិត្យមើលសំណុំរឿង០០៤[7] ដោយមូលហេតុថា វាជាការចាំបាច់ ក្នុងការធានាដល់សិទ្ធិរបស់គាត់ ក្នុងការទទួលបាននូវការប្រព្រឹត្តស្មើគ្នារវាងអ្នកមិនមែនជាភាគីនៃ សំណុំរឿង០០៤ សច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចនីតិវិធី ("សំណើសុំពិចារណាឡើងវិញ")[8]។

5. នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យប្រើកំណត់ហេតុស្តាប់ចម្លើយ សាក្សីចំនួន២៧ នៅក្នុងសំណុំរឿង០០២/០២[9]។

II. បណ្តឹងឧទ្ធរណ៍

6. នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១៥ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើរបស់គាត់សុំ ពិចារណាឡើងវិញ[10] ហើយនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ គាត់បានដាក់សារណាបណ្តឹង ឧទ្ធរណ៍។ ម្ចាស់បណ្តឹងឧទ្ធរណ៍ផ្តល់ទឡ្ហីករណ៍ថា ការពន្យារពេលរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងការសម្រេចទៅលើសំណើសុំពិចារណាឡើងវិញ គឺជាការបដិសេធតាមការសន្មត ហើយនាំ ដល់ការបន្តរំលោភសិទ្ធិទទួលបានសមភាព សច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចនីតិវិធី។ គាត់ក៏ ផ្តល់ទឡ្ហីករណ៍ផងដែរថា សេចក្តីសម្រេចលើសំណើសុំពិនិត្យឡើងវិញរបស់គាត់ គឺត្រូវការជា ចាំបាច់ មុនថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ទៅទៀត ដែលនៅក្នុងកាលបរិច្ឆេទនោះ សវនាការក្នុង

---

[7] សំណើបន្ទាន់របស់ [redacted] សុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីនៃ សំណុំរឿង ០០៤ នៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D229។

[8] ដូចខាងលើ កថាខណ្ឌ។

[9] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកឯកសារដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និង មន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីបង្គាប់ស្តីពីការប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ E319/7។

[10] ការជូនដំណឹងរបស់ [redacted] អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើបន្ទាន់របស់គាត់សុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីនៃ សំណុំរឿង ០០៤ នៅក្នុងសំណុំរឿង ០០២/០២ ឯកសារ D229/1 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤។

E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

សំណុំរឿង០០២/០២ ត្រូវបានកំណត់ថ្ងៃចាប់ផ្តើម "ដើម្បីជៀសវាងការប្រើចម្លើយសាក្សីក្នុងសំណុំរឿង០០២/០២ ដែលមានសក្តានុពលមិនអាចទទួលយកបាន"[11]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ផ្តល់ទឡ្ហីករណ៍ថា បណ្តឹងឧទ្ធរណ៍របស់គាត់អាចទទួលយកបានតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីធានានូវការគោរពសិទ្ធិទទួលបានសមភាព សច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចនីតិវិធី។ ម្ចាស់បណ្តឹងឧទ្ធរណ៍អះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានតម្លាភាព ថាតើគាត់ចាត់ទុកថាការដាក់បង្ហាញសម្ភារៈពីសំណុំរឿង០០៤ ដល់អ្នកមិនមែនជាភាគី ជាគ្រោះថ្នាក់សម្រាប់ការស៊ើបអង្កេតក្នុងសំណុំរឿងនេះ ដោយហេតុថាកាលពីមុនគាត់បានចាត់ទុកថាការដាក់បង្ហាញសម្ភារៈលើសំណុំរឿង០០៤ ដល់អ្នកមិនមែនជាភាគី គឺជាការគ្រោះថ្នាក់ដល់ការស៊ើបអង្កេតក្នុងសំណុំរឿង០០៤ តែផ្ទុយទៅវិញ ថ្មីៗនេះគាត់បានអនុញ្ញាតឱ្យដាក់បង្ហាញនូវចម្លើយសាក្សីចំនួន២៧ ដល់អ្នកមិនមែនភាគីហើយថ្លែងថា "ដំណើរវិវត្តនានាក្នុងការស៊ើបអង្កេតសំណុំរឿង០០៤ ដែល[បាន]កាត់បន្ថយសេចក្តីព្រួយបារម្ភមួយចំនួនអំពីភាពសម្ងាត់ ទាក់ទងនឹងសម្ភារៈដែលបានស្នើ" ដោយពុំមានការពន្យល់បន្ថែមអ្វីឡើយ[12]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ផ្តល់ទឡ្ហីករណ៍ទៀតថា សហចៅក្រមស៊ើបអង្កេតកំពុងដាក់កំហិតផ្សេងៗគ្នា លើការដាក់បង្ហាញដល់អ្នកមិនមែនជាភាគីក្នុងសំណុំរឿង០០៤ ដែលប៉ះពាល់ដល់សិទ្ធិរបស់អ្នកមិនមែនជាភាគីនៃសំណុំរឿង០០៤ ក្នុងការទទួលបានការប្រព្រឹត្តស្មើគ្នាចំពោះមុខច្បាប់ និងដែលជាលទ្ធផលនាំឱ្យមានអសច្ចភាពផ្លូវច្បាប់[13]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើឱ្យអង្គជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍ និងស្នើឱ្យ ក) លុបចោលការដាក់បង្ហាញចម្លើយសាក្សីចំនួន២៧ ឬ ខ) ផ្តល់មេធាវីនូវការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿង០០៤។

7. សហព្រះរាជអាជ្ញា ឬ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬដើមបណ្តឹងរដ្ឋប្បវេណី ពុំបានដាក់ចម្លើយតបតាមពេលវេលាកំណត់តាមច្បាប់ឡើយ។

[11] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៩។

[12] ដូចខាងលើ កថាខណ្ឌ ១២-១៣។

[13] ដូចខាងលើ កថាខណ្ឌ ១៤។

III. ការទទួលយកបណ្តឹងឧទ្ធរណ៍

8. ម្ចាស់បណ្តឹងឧទ្ធរណ៍មិនជំទាស់ទៅនឹងសេចក្តីសម្រេចមួយរបស់សហចៅក្រមស៊ើបអង្កេតទេ ប៉ុន្តែជាងនេះទៀតអះអាងថា ការពន្យារពេលក្នុងការសម្រេចទៅលើសំណើសុំពិចារណាឡើងវិញ គឺជាការបដិសេធតាមការសន្មតទៅលើសំណើដែលបានលើកឡើង ហើយបើកលទ្ធភាពក្នុងការប្តឹងឧទ្ធរណ៍។ អង្គបុរេជំនុំជម្រះរំលឹកថា អនុលោមតាមវិធាន៧៣ និងវិធាន៧៤ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះមានយុត្តាធិការ ស្តាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេច ឬដីការបស់សហចៅក្រមស៊ើបអង្កេត។ ក៏ប៉ុន្តែ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលដែលសហចៅក្រមខកខានមិនបានសម្រេចទៅលើសំណើមួយក្នុងរយៈពេលកំណត់ដោយច្បាប់ ឬពេលដែលការពន្យារការចេញសេចក្តីសម្រេចពុំមានហេតុផល និងដកហូតនូវលទ្ធភាពរបស់ភាគីស្នើសុំ ក្នុងការទទួលបានផលប្រយោជន៍ដែលខ្លួនចង់បាននោះ ជាករណីលើកលែង បញ្ហានេះនឹងដាក់ជូនអង្គបុរេជំនុំជម្រះ ប្រសិនបើបញ្ហានោះស្ថិតក្នុងយុត្តាធិការលើរឿងក្តីរបស់ខ្លួន[14]។ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា ចំណុចទីពីរគឺអនុវត្តចំពោះស្ថានភាពបច្ចុប្បន្ន ដោយហេតុថា ដំណោះស្រាយបន្ទាន់ចំពោះបញ្ហាដែលលើកឡើងនៅក្នុងសំណើសុំពិចារណាឡើងវិញនេះ គឺជាការចាំបាច់សម្រាប់បញ្ចៀសប្រការដែលថា អង្គជំនុំជម្រះសាលាដំបូងប្រើចម្លើយសាក្សីក្នុងសំណុំរឿង០០២ ដែលក្រោយមកអាចគេរកឃើញថា មិនអាចទទួលយកបាន និងដើម្បីបញ្ចប់នូវការបន្តរំលោភសិទ្ធិរបស់គាត់ ក្នុងការទទួលបានការប្រព្រឹត្តស្មើគ្នា សច្ចភាពផ្លូវច្បាប់ និងតម្លាភាពកិច្ចនីតិវិធី[15]។ អង្គបុរេ

---

[14] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") (អបជ១០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ A189/I/8 កថាខណ្ឌ ២២-២៤។ ឧទាហរណ៍ សូមមើលផងដែរ សំណុំរឿង ០០៤ (អបជ១២) សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតសំណើទីបួនរបស់ [redacted] សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៨។ សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ១០) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D87/2/2 កថាខណ្ឌ ១០-១១។ សំណុំរឿង ០០២ (អបជ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំ D153, D172, D173, D174, D178 & D284 (សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ របស់ នួន ជា) ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ D300/1/5 កថាខណ្ឌ ២០។

[15] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧ និង ៩។

ជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍ទាំងពីរពុំមានមូលដ្ឋាននាំឲ្យជឿបាន។ ចំពោះទឡ្ហីករណ៍ទីមួយ អង្គបុរេជំនុំជម្រះយល់ឃើញថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ដែលមិនមែនជាភាគីនៃរឿងក្ដី០០២/០២ ពុំមានសិទ្ធិលើកឡើងនូវបញ្ហានានា ទាក់ទិននឹងការទទួលយកភស្តុតាងនៅក្នុងរឿងក្ដីនេះ ហើយនឹងមិនអាចទទួលរងផលប៉ះពាល់ ប្រសិនបើនៅពេលក្រោយ ភស្តុតាងត្រូវបានរកឃើញថា មិនអាចទទួលយកបាន។ ចំពោះទឡ្ហីករណ៍ទីពីរ អង្គបុរេជំនុំជម្រះយល់ឃើញថា ការពន្យារក្នុងការចេញសេចក្ដីសម្រេចលើសំណើសុំពិចារណាឡើងវិញគឺពុំមែន ពុំមានហេតុផលនោះទេនៅក្នុងកាលៈទេសៈទាំងនេះ ហើយម្ចាស់បណ្ដឹងឧទ្ធរណ៍ពុំបានបង្ហាញថា សិទ្ធិដែលគាត់បានអះអាងមានហានិភ័យនឹងទទួលរងនូវផលប៉ះពាល់ដែលមិនអាចដោះស្រាយបាននោះទេ។

9. ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្ដឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ។

IV. សេចក្ដីសម្រេច

អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖

បដិសេធបណ្ដឹងឧទ្ធរណ៍នេះថាមិនអាចទទួលយកបាន។

អនុលោមតាមវិធានផ្ទៃក្នុង៧៧(១៣) សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៤

ប្រធាន **អង្គបុរេជំនុំជម្រះ**

E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ប្រាក់ គឹមសាន **Steven J. Bwana** **ន័យ ធុល** **Chang-ho CHUNG** **ហួត វុទ្ធី**

សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតលើសំណើសុំពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីនៃសំណុំរឿង០០៤ នៅក្នុងសំណុំរឿង០០២/០២